# ក្រោយថ្ងៃ១៨មិនា១៩៧០

# កម្ពុជាធ្លាក់ចូលក្នុងមហាអន្តរាយ!

### អត្ថបទដកស្រង់ចេញពីសៀវភៅសិក្សាស្រាវជ្រាវ «Cambodge, Le Chemin de l'Apocalypse» បោះពុម្ពផ្សាយជាភាសាបារាំង នៅក្នុងសារពត៌មាន«អង្គរបូរី» កាលពីឆ្នាំ១៩៩៨

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី៣ កក្កដា ២០០៥

ក្នុងរយ:ពេលតែមួយសប្តាហ៍ប៉ុណ្ណោះសោះ បន្ទាប់ពីមានការទម្លាក់សម្តេចសីហនុពីមុខដំណែង សង្គ្រាមបានចូលមកសន្ធិតដល់មាត់ទ្វារនៃប្រទេសខ្ញុំរួចទៅហើយ ដែលកំពុងតែដេកលក់ ។ សង្គ្រាមនេះវាមកដល់លឿនពន់ប្រមាណ លឿនហួសហេតុពេកណាស់ ដែលគេមិនអាចសន្និដ្ឋានបានថា វាកើតឡើងដោយឯងៗ ។ សង្គ្រាមនេះដែលហក់មកដល់ប្រទេសកម្ពុជាដូចរន្ទះបាញ់កណ្តាលថ្ងៃត្រង់ ដោយជនជាតិខ្មែរគ្មានទាំងមានពេលរៀបចំខ្លួនប្រឈមមុខទៀតផង... ជារឿងមួយមិនគួរឲ្យយល់បានសោះ...ឧបមាថា, បើយោងតាមគំនិតអ្នកផង, កំហុសនៃការបង្កបង្កើតកលិយុគ វាបណ្តាលមកពីឧត្តមសេនិយលន់-នល់ (ការកាប់សម្លាប់យួន) ឬក៏បណ្តាលមកពីអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមត: (ការទម្លាក់ស្តេចសីហនុ) ។

ប៉ុន្តែរឿងនេះ គេអាចយល់បានស្រួលណាស់ ហើយលេចឡើងយ៉ាងច្បាស់ត្រឡែតទៀតផង, បើឧបមាថាសង្គ្រាមនេះ វាបានផ្ទុះឡើងតាមឆន្ទ:របស់វៀត-ណាមខាងជើង ។ គឺពីព្រោះថា សង្គ្រាមនេះបានរៀបចំធ្វើឡើងយ៉ាងល្អិតល្អន់ តាមផែនការរបស់ហូ-ជីមិញ ។ ដោយហេតុថា សង្គ្រាមបានហក់មកដល់ប្រទេសកម្ពុជាភ្លាមមួយរំពេច ប្រកបដោយល្បឿននៃសេះប្រណាំង បន្ទាប់ពីថ្ងៃ១៨មិនា១៩៧០, គឺមកពីថ្ងៃនេះជាថ្ងៃជ្រើសរើសរបស់ពួកយួនឈ្លានពាន ។ សង្គ្រាមនីមួយៗមិនដែលកើតឡើងដោយចៃដន្យនោះទេ ។ ពួកវៀតណាមកុម្មុយនិស្តមានល្បិចកល ហើយពូកែធ្វើការគន់គូរអស្ចារ្យ ពួកគេពុំមានពឹងផ្អែកទៅលើការហេងស៊ យសូម្បីតែបន្តិចបន្តួចក៏គ្មានផង ។ គួរជ្រាបថា នៅពេលនោះ ពុំមានកងទ័ពអាមេរិកាំងនៅប្រទេសកម្ពុជានៅឡើយទេ ហើយបើថ្ងៃក្រោយមក កងទ័ពនេះបានរត់ចូលមកយ៉ាង«ប្រផាប់ប្រភឹង»ក្នុងទឹកដីកម្ពុជា ដែលត្រូវឡោមព័ទ្ធជុំជិតដោយពួកកុម្ម-

យនិស្តទៅហើយ... គឺព្រោះតែលោកប្រធានាធិបតី និចសុន បានចូលអន្ទាក់របស់គេ ។ ហើយនៅក្នុងពេលជាមួយគ្នា ដែលពួកអាមេរិកាំងបានត្រូវចាញ់បញ្ឆោតនោះ សារពត៌មានបរទេសទាំងអស់បានត្រូវបង្វិលខួរក្បាលអស់រលីងរួចទៅហើយដែរ ។ ទោះជាយ៉ាងណាក្តី ពួកអាមេរិកាំងកំពុងតែស្វះស្វែងរកច្រកចេញពីផ-ណ្តួចិន... ចំណែកពួកវៀតណាមវិញ បានជ្រើសរើសយកដំណោះស្រាយយោធារួចទៅហើយ នៅប្រទេសកម្ពុជា ៖ គឺនយោបាយធ្វើសង្គ្រាម ។ ពោលគឺពួកគេបានធ្វើសេចក្តីសំរេចតាំងពីយូរណាស់មកហើយ ពុំមែនចេះតែដើរផ្សងព្រេង (ចូលមកក្នុងស្រុកខ្មែរ) ដោយងងឹតងងល់ឬទាំងខ្វាក់នោះទេ ។

ដើម្បីមានលទ្ធភាពបង្កើតសឹកសង្គ្រាមបាននៅប្រទេសកម្ពុជា... គេត្រូវមានកត្តាសំខាន់ពីរយ៉ាង ដូចនៅក្នុងគណិតសាស្ត្រដូច្នោះឯង គឺកត្តាចាំបាច់ (Une con dition nécessaire) និងកត្តាគ្រប់គ្រាន់ (Une condition suffisante) ។ ពួកវៀតណាមមានកត្តាចាំបាច់រួចទៅហើយ ដោយហេតុថាពួកគេមានកងកម្លាំងសំរាប់ប្រយុទ្ធ ២០០,០០០នាក់ នៅក្នុងទឹកដីកម្ពុជា ។ ក៏ប៉ុន្តែពួកគេក៏មាននៅក្នុងកណ្តាប់ដៃ នូវកត្តាគ្រប់គ្រាន់ផងដែរ ៖ គឺសម្តេចសីហនុ, មេដំបែនៃលទ្ធិកុម្មុយនិស្តអាស៊ីកិត្តិនាមអន្តរជាតិ, ល្បិចកលគ្រប់បែបយ៉ាង...។ សម្តេចសីហនុមិនត្រឹមតែបានដើរតួជាឈ្មាន់របស់ពួកយួនប៉ុណ្ណោះទេ គាត់នេះក៏ធ្លាប់ធ្វើភ្នាក់ងារប្រកបដោយបញ្ញាញៀនរបស់វៀតណាមកុម្មុយនិស្តថែមទៀត (តាំងពីកាលណាមក...ខ្ញុំគ្រាន់តែអាចសន្និដ្ឋានប៉ុណ្ណោះ... ប្រហែលតាំងពីសម័យទាមទារឯករាជ្យនៃឆ្នាំ១៩៥៣មកម្ល៉េះ, ប៉ុន្តែនេះជារឿងសំរាប់សរសេរសៀវភៅមួយទៀត) ។ រហូតដល់ចុងចប់ សម្តេចបានធ្វើឲ្យជនជាតិខ្មែរទាំងមូល ស្ថិតនៅក្នុងសភាពឥតគ្រឿងអាវុធការពារខ្លួន ។ ដោយត្រូវដងត្រូវផ្លែជាមួយនឹងផាំ-យ៉ាំងដុំងគ្រប់ជំហាន ស្តេចសីហនុបានបង្វិលខួរក្បាល តាំងពីរដ្ឋាភិបាលស្រោចស្រង់ជាតិ ពួកបណ្ឌាមុខមន្ត្រីនិងពួកអ្នកចេះដឹងខ្មែរទាំងអស់ ដើម្បីឲ្យពួកគេធ្លាក់ចូលទៅក្នុងសំណាញ់របស់យួនឈ្លានពាន គឺដូចតែសត្វត្រី ដែលល្មមដល់ពេលយកទៅចៀនបរិភោគដូច្នោះឯង ។

⌘

⌘ ⌘

នៅថ្ងៃទី២០មិនា១៩៧០, ប្រជាជនទាំងឡាយនៅទីក្រុងភ្នំពេញ មានសេចក្តីភិតភ័យញាប់ញ័រផ្អើលស្រឡាំងកាំង នឹងសេចក្តីស្លាប់របស់លោកវរសេនិយឯក សេង-ស៊ុនថៃ អគ្គនាយកនៃទីចំណាត់ការ (Transmission) នៃកងទ័ពខ្មែរដែលត្រូវគេធ្វើឃាតដោយអាថ៌កំបាំង ។ គឺជានាយទាហានជាន់ខ្ពស់ទី១ ដែលបានត្រូវគេសម្លាប់ បន្ទាប់ពីថ្ងៃទី១៨មិនា១៩៧០ ។ ពួកអ្នកគាំទ្រស្តេចសីហនុបានចោទថា គឺពួកលន់-នល់ដែលបានប្រព្រឹត្តឃាតកម្មនេះ ដោយមកពីហេតុថា លោកលន់-នល់ស្អប់លោកសេង-ស៊ុនថៃ ។ ចំណែកពួកគាំទ្រឧត្តមសេនិយលន់-នល់បាន

ចោទថា ជាទង្វើរនស់ពួកស្ដេច ដោយហេតុថា សេង-ស៊ុនថៃមានខ្សែអាត់សម្ងាត់ ដែលជាបញ្ជារបស់ស្ដេចសីហនុ ឲ្យពិឃាតពួករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលលន់-នល់ទាំងអស់... ជាពិសេសគឺអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមត: ។ ប៉ុន្ដែមានពាក្យចចាមអារាមផ្សេងទៀតដែលបានចោទថា គឺពួកយៀកកុងទៅវិញទេ ជាអ្នកសម្លាប់រូបលោក ដោយហេតុថា លោកសេង-ស៊ុនថៃមានជីវិតរស់នៅអបាយមុខ ។ គាត់ចូលចិត្តដើរលេងកំសាន្តសប្បាយនៅក្នុងរង្គសាល ហើយមានចិញ្ចឹមស្រីកំណាន់យៀកណាមជាច្រើននាក់ទៀតផង ។

ប៉ុន្ដែហេតុអ្វីបានជាគេជ្រើសរើសយករូបលោកសេង-ស៊ុនថៃ ដែលជានាយទាហានមួយរូបពុំមាននរណាស្គាល់ផង ? ហេតុអ្វីបានជាគេមិនបានចាត់ការលោកសុស្ដែន-ហ្វៀរណង់ដែស ឬក៏លោកអ៊ុំ-ម៉ាណូរិនវិញទៅ ដែលជាសសរទ្រូងទាំងពីរអង្គនៃរបបផ្ដាច់ការនិយមរបស់ស្ដេចសីហនុ ? ឃើញថា រដ្ឋប្រហារនេះលេចឡើងជារឿងកំប្លែងសុទ្ធសាធ (!!) ។

⌘

⌘ ⌘

ថ្ងៃទី២៣, ២៤, ២៥មិនា, ពួកជនជាតិខ្មែរហាក់ដូចជានៅដេកលក់ស្កប់ស្កល់នៅឡើយ ។ ទិវារាត្រីបានកន្លងទៅដោយស្ងាត់ស្ងៀម ។ ក្នុងប៉ុន្មានថ្ងៃនេះ គ្មានអ្វីកើតឡើងសោះនៅប្រទេសកម្ពុជា ។ លោកឧត្ដមសេនិយលន់-នល់គ្មានបានធ្វើអ្វីទាំងអស់ ក៏ប៉ុន្ដែនរណាៗក៏បានសរសើររូបលោកថា ជាអ្នកមានជោគជ័យក្នុងប្រការបានធ្វើបដិវត្តន៍មួយដោយគ្មានបង្ហូរឈាម ។ ក្រៅតែពីការវាយប្រហារទៅលើពួកយួនដោយពាក្យសំដី, ពួករដ្ឋមន្ត្រីនស់លន់-នល់ ដោយភ័យខ្លាចសម្ដេចសីហនុយាងត្រឡប់មកវិញ ក៏នៅពួកសម្ងំក្នុងប៊ុយរ៉ូរបស់ខ្លួន ដូចសត្វដែលសម្ងំនៅក្នុងរូង ។ ចំពោះពួកជនដែលគេចោទថា បានធ្វើរដ្ឋប្រហារ គឺជាអាកប្បកិរិយាមួយដ៏ចម្លែកពន់ពេក ។

⌘

⌘ ⌘

រំពេជនោះ, នៅថ្ងៃទី២៦មិនា មហន្តរាយក៏ស្រាប់តែលាន់សូរខ្លាំង ប្រហែលគ្នានឹងគ្រាប់បែកដែលគេពន្យារពេលឲ្យផ្ទុះ ៖ ពោលគឺមានបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាល និងការបះបោរដ៏កាចសាហាវមួយនៅខេត្តកំពង់ចាម ដែលបំផុសបំផុលឡើងដោយពួកភ្នាក់ងារយៀកកុង ។ នៅក្នុងការិយាល័យរបស់ខ្ញុំនៅភ្នំពេញ, ខ្ញុំបានស្ដាប់សេចក្ដីរាយការណ៍របស់អ្នកដំណើរ (ពីរបីថ្ងៃក្រោយមក) ដោយសេចក្ដីស្លុតរន្ធត់បះសក់ព្រោង។ គឺហាក់ដូចជាពួកយៀកកុងបានធ្វើការសងសឹកចំពោះពួកយើងវិញ ដោយសងថ្លៃមួយជា១០០ដូច្នោះឯង ។ ពួកបាតុករមានគ្នាច្រើនខ្លាន់ខ្លាប់ប្រមាណជា១សែននាក់ ជិះទូកឆ្លងទន្លេមេគង្គឡើងខ្មៅងងឹត ពីទន្លេបិទមក

កំពង់ចាមក្រុង ។ នៅក្រោមក្រសែភ្នែកដ៏ស្រទ្បាំងកាំងហួសចិត្តនៃពួកយោធាដែលបានទទួលបង្គាប់ពីអគ្គមេបញ្ជាការ «មិនឲ្យធ្វើការបង្ក្រាបទៅលើប្រជាពលករដោយប្រើគ្រឿងអាវុធ», ពួកក្រុមបះបោរដែលតាំងខ្លួនថាជាពួកក្រុមសីហនុនិយមក៏បានកាប់សម្លាប់បងប្រុសលោកឧត្តមសេនិយលន់-នល់ ឈ្មោះហ៊ិន-និល នៅចំការកៅស៊ូជប់ មិនឆ្ងាយប៉ុន្មានពីទន្លេបិទ ហើយក៏បានវះពោះពុះដើមទ្រូងអ្នកតំណាងរាស្ត្រពីរនាក់ផងដែរ គឺលោកគឹម-ផុន និងលោកសុស-សាអុន នៅមុខសាលាខេត្តកំពង់ចាម ។ នៅក្នុងរយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះសោះ ដោយរដ្ឋាភិបាលលន់-នល់ពុំទាន់មានលទ្ធភាពធ្វើអ្វីទាំងអស់, សន្តិភាពនៃប្រទេសកម្ពុជាក៏បានធ្លាក់រមៀលចូលទៅក្នុងសេចក្តីវិនាសអន្តរាយរួចជាស្រេច ។

ពួកក្រុមប្រជាកសិករ ដែលប្រដាប់ដោយកាំបិតផ្គាក់គ្រប់ដៃ ហើយដែលត្រូវគេបញ្ឆោតស្រាស្រវឹង ទោះមិនដឹងខ្លួនក៏ដោយ មានក្របខណ្ឌយួនជាអ្នកនាំអាទិ ក៏ត្រូវបានកើនចំនួនរីកធំប៉ោងឡើងដូចទឹកជំនន់ ហើយនៅថ្ងៃទី២៧មិនាក៏បានធ្វើដំណើរឆ្ពោះមករដ្ឋធានីភ្នំពេញដែលកំពុងតែក្លាយទៅជាទីក្រុងដែលពួកកុម្មុយនិស្តឡោមព័ទ្ធ ។ នៅទីបំផុត លោកឧត្តមសេនិយលន់-នល់ក៏បានសំរេចបញ្ជាឲ្យលោកស្រី-យ៉ា វរសេនិយទោផ្នែកកងឆ័ត្រយោងឲ្យបំបែកការឡោមព័ទ្ធនៃពួកក្រុមបះបោរនៅចុងស្ពានជ្រោយចង្វារ ដោយធ្វើការបាញ់រះទៅលើពួកប្រជាជន ដែលកំពុងឆេះរោលរាលដោយហឹង្សា ។ នេះគឺជាការឡោមព័ទ្ធដ៏មហាបិសាចរបស់ពួកយៀកកុង ។

នៅពេលនោះ សភាពត្រឹមត្រូវស្របច្បាប់នៃ«រដ្ឋាភិបាលស្រោចស្រង់ជាតិ» របស់លោកឧត្តមសេនិយលន់-នល់ (ការបំផុសបំផុលប្រជាពលករឲ្យងើបឡើងធ្វើបាតុកម្មដេញយួនឈ្លានពាន តាមបង្គាប់បញ្ជារបស់ស្តេចសីហនុ) ក៏ត្រូវបានទទួលបរាជ័យធ្លាក់ទឹកទាំងស្រុង ។ ប្រទេសកម្ពុជាបានរមៀលធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលរួចទៅហើយ ។ គឺការបាញ់រះឡើងលើនេះឯង គ្រាប់កាំភ្លើងដ៏ពិតប្រាកដហើយដែលគេមើលឃើញទាំងកណ្តាលថ្ងៃត្រង់ គ្រាប់កាំភ្លើងដែលហោះហើរច្រវាត់ ដោយភ័យខ្លាចនិងដោយខ្វាក់ ដែលបានចិញ្ចឹមការឃោសនារបស់ខ្មាំងយួន ដែលបានចោទរបបលន់-នល់ថា ជារដ្ឋការ«ឃាតករហ្វាស៊ីស្ត» ទៅលើប្រជាជនខ្លួនឯង ។ ប៉ុន្តែការសម្លាប់ដ៏រង្គាលព្រៃផ្សៃផ្សេងៗទៀត ដែលប្រព្រឹត្តទៅលើប្រជាជនស៊ីវិលខ្មែរក្តី យួនក្តី ពុំមែនជាស្នាដៃរបស់រដ្ឋការសាធារណរដ្ឋអណ្តែតទឹកនោះទេ ។ គឺដូចជានាវាមួយឃ្លេងឃ្លោងរកកលនឹងលិច, រដ្ឋាភិបាលនេះក៏ដូចជាអគ្គមេបញ្ជាការរបស់ខ្លួនដ៏ទន់ភ្លន់និងយល់សប្តិយល់សួង្ស ដែលចេះតែពីរត់តាមក្រោយព្រឹត្តិការណ៍ប៉ុណ្ណោះ គឺមិនត្រឹមតែមិនមែនជារដ្ឋាភិបាលព្រៃផ្សៃប៉ុណ្ណោះទេ ថែមទាំងពុំមានមធ្យោបាយនិងពេលវេលាគ្រប់គ្រាន់ ដើម្បីព្រឹត្តិការណ៍ពិឃាតរង្គាលឆ្កួតៗ ទៅលើប្រជាជនវៀតណាមកាតូលិកផងទៀត ។ ពីព្រោះការ

ប្រហារជីវិតមនុស្សទាំងហ្វូងទាំងហ្វាយនេះ ដែលកើតមានឡើងភ្លាមបន្ទាប់ពីការទម្លាក់ស្ដេចសីហនុ ក៏បានបង្កើតឲ្យមានសេចក្ដីខ្ពើមរអើមហួសប្រមាណពីសំណាក់ក្រុមបញ្ញវ័ន្តឆ្វេងនិយមអន្តរជាតិចំពោះរដ្ឋាភិបាលលន់-នល់ ដោយគេបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនេះវារាលដាលចេញមកពីបាតុកម្មវាយប៉ានទូតយួនកុម្មុយនិស្តទាំងពីរ ។ ក៏ប៉ុន្តែនៅក្នុងប្រការដែលថា ពួកយួនដែលត្រូវសម្លាប់នៅក្នុងជួរដំបូងនិងជួរទី២ គឺសុទ្ធសឹងតែជាពួកវៀតណាមកាតូលិក ព្រមទាំងពួកប្រឆាំងនឹងកុម្មុយនិស្តទៀតផង ។ ការប្រហារទាំងនេះក៏បានប្រទាញជាលទ្ធផលចុងចប់ នូវអមិត្តភាពដ៏ជ្រាលជ្រៅពីពួកស្ដាំនិយមថែមទៀត ។ តែក្នុងពីរបីថ្ងៃប៉ុណ្ណោះសោះ លោកឧត្តមសេនិយលន់-នល់បានប្រទាញឲ្យធ្លាក់មកលើខ្លួនលោក នូវការផ្ដន្ទាទោសរបស់ពិភពលោកទាំងមូល ។ រឿងនេះ វាច្បាស់ជាពុំមែនរូបលោកទេដែលជាបុព្វហេតុដើម ។ រដ្ឋាភិបាលរបស់លោកមានការភិតភ័យបារម្ភ តែចំពោះការវិលត្រឡប់មកវិញរបស់សម្ដេចសីហនុ ហើយមានអាកប្បកិរិយាត្រឹមតែលាក់ខ្លួនពួនសម្ងំតែប៉ុណ្ណោះឯង ។

ខ្ញុំសូមលើកយកអត្ថបទខ្លះៗរបស់ «Réalités Cambodgiennes» សារពត៌មានរដ្ឋប្រចាំសប្ដាហ៍ ជាភាសាបារាំង ចេញផ្សាយនៅថ្ងៃ៥មេសា១៩៧០ នៅក្រុងភ្នំពេញ ដែលលាតត្រដាងបង្ហាញអំពីព្រឹត្តិការណ៍កើតឡើងនៅប្រទេសកម្ពុជាបន្ទាប់ពីថ្ងៃ១៨មិនា១៩៧០, ដើម្បីគ្រាន់តែបង្ហាញថា វាមានពេលវេលាអសកម្មភាពមួយរយៈដ៏ធំ (un temps mort) បន្ទាប់ពីរដ្ឋប្រហារដែលគេបានចោទឧត្តមសេនិយលន់-នល់ ថាជាអ្នកបានប្រព្រឹត្ត ។ ដូច្នេះគេបានវិនិច្ឆ័យបានក្នុងភាពក្ដៅៗ នូវសកម្មភាពនៃរដ្ឋាភិបាលមួយ ដែលគេចាត់ទុកថាជា«បដិវត្តន៍» ហើយដែលត្រូវមានលទ្ធភាពបង្កើតស្ថាប័ននៃសាធារណរដ្ឋ ។ គេបានសង្កេតឃើញថា លោកឧត្តមសេនិយអគ្គមេបញ្ជាការកងទ័ព ព្រមទាំងនាយកនៃរដ្ឋាភិបាលបានស្ថិតនៅក្នុងសភាពស្ងៀមស្ងាត់និងអសកម្មនៅចំពោះមុខទំហំធំធេងនៃព្រឹត្តិការណ៍កំបុតត្បូង រីឯចំណាត់ការទាំងប៉ុន្មាន វាវិលចេញមកពីពួកខាងម្ខាងទៀតវិញសោះ គឺសម្ដេចសីហនុនិងពួកយៀកកុង ។

គេបានសង្កេតឃើញផងដែរថា រយៈពេលពីរសប្ដាហ៍បានកន្លងផុតទៅហើយ បន្ទាប់ពីការទម្លាក់សម្ដេចសីហនុពីមុខតំណែង ក៏ប៉ុន្តែនៅក្នុងទំព័រពាណិជ្ជកម្មមួយនៃ Réalités Cambodgiennes (ដែលជាសារពត៌មានរបស់រដ្ឋាភិបាល) ចុះថ្ងៃទី៤មេសា១៩៧០ មានបង្ហាញរូបសម្ដេចសីហនុព្រះប្រមុខរដ្ឋ និងរូបព្រះមហាក្សត្រីយានីកុសុមៈ, ជាព្រះមាតាជាតិ ។ ព្រឹត្តិការណ៍ដ៏តូចមួយនេះ ដែលគេអាចមើលរំលងបានយ៉ាងស្រួល (ប្រហែលបើគេមិនផ្ដោតអារម្មណ៍) បានធ្វើឲ្យផុះលេចចេញឡើងនៅក្នុងស្ថានភាពលក្ខណៈដ៏សែនកំសត់អស្ចារ្យ អំពីសេចក្ដីស្មោះត្រង់និងសភាពឥតទោសពៃរ៍ របស់រដ្ឋាភិបាលលន់-នល់ ទាក់ទងនឹង«រដ្ឋប្រហារនៃ

ថ្ងៃ១៨មិនា១៩៧០» ។ រដ្ឋាភិបាលនេះ មិនដែលបានទទួលយល់ព្រមយកពាក្យថា «រដ្ឋប្រហារ»នោះឡើយ តែបាននិយាយថាជា «ព្រឹត្តិការណ៍នៃថ្ងៃទី១៨មិនា» ។ ម្ល៉ោះហើយដោយលោកឧត្តមសេនិយមិនមែនជាអ្នកដើមចមនៃរដ្ឋប្រហារ លោកក៏មិនបានធ្វើពិធី«កាប់សម្លាប់យួន»ជាមួយគ្នានោះផងដែរ ។ ឧក្រិដ្ឋកម្មទាំងពីរមុខនេះ មិនមែនរូបលោកទេជាអ្នកប្រព្រឹត្ត ។ ដោយហេតុថាព្រឹត្តិការណ៍ទាំងពីរនេះត្រូវចងជាប់គ្នា ជាបុព្វហេតុចាំបាច់ដែលជំពាក់វាក់វិនគ្នាចាក់ស្រេះបណ្តាលឲ្យមានសង្គ្រាមប្រល័យពូជសាសន៍ខ្មែរ ម្ល៉ោះហើយគឺជារឿងព្រឹត្តិការណ៍ដែលបានត្រូវរៀបចំឡើងយ៉ាងល្អិតល្អន់ ដោយកងកម្លាំងតែមួយដែលគេមើលមិនឃើញ ហើយដែលតែងលាក់ខ្លួនគ្រប់ពេលវេលា នៅពីក្រោយខ្នងសម្តេចសីហនុ ៖ គឺពួកវៀតណាមកុម្មុយនិស្ត ។ ឧក្រិដ្ឋកម្មតែងតែផ្តល់ចំណេញទៅអ្នកប្រព្រឹត្ត ហើយសង្គ្រាមនេះ មិនបានផ្តល់ចំណេញទាល់តែសោះទៅដល់ជនជាតិខ្មែរ ។

ពួកយួនខាងជើងបានបាញ់ប្រហារពួកវៀតណាមកាតូលិកទម្លាក់ទឹក រួចហើយក៏លើកយកឧក្រិដ្ឋកម្មនេះទម្លាក់ទៅលើលោកលន់-នល់, ភ្លាមបន្ទាប់ពីបាតុកម្ម (វាយស្ថានទូតយួន) នៃថ្ងៃទី១១មិនា១៩៧០, ជាសញ្ញាឲ្យកងទ័ពយួនចូលលុកលុយរាតត្បាតប្រទេសកម្ពុជា ពីព្រោះគឺជាសញ្ញាមួយដ៏ពិតប្រាកដណាស់ (!!) ។

គឺទំនាក់ទំនង សភាពជំពាក់វាក់វិនរវាងព្រឹត្តិការណ៍ពីរដែលផ្ទុះឡើងនៅពេលតំណាលគ្នា ៖ ការទម្លាក់សម្តេចសីហនុពីមុខតំណែង និងការសម្លាប់យួននេះហើយ គឺជាបរិយាន-បរិយោសាន, ចំណុចចុងក្រោយ, គន្លឹះដ៏សំខាន់ជាងគេបំផុតនៅក្នុងមហាអាថ៌កំបាំងនៃប្រវត្តិសាស្ត្រ១៨មិនា, ជាកូនសោរសំរាប់មួលបើកគ្រប់ច្រកទ្វារនៃសេចក្តីពិត ហើយដែលបានរបូតគេចផុតពីក្រសែភ្នែករបស់ខ្ញុំចំនួនក្បែរ ៣០ឆ្នាំមកហើយ ។ ទំនាក់ទំនងខាងលើនេះបានបង្ហាញឲ្យឃើញថា របាំរេរាំសំរាប់ប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា បានត្រូវគ្រោងរៀបចំឡើងយ៉ាងម៉ត់ចត់ក្រៃលែងដោយពួកជនជាតិយួន ។ ចំណែកជនជាតិខ្មែរទាំងអស់គ្រាន់តែបានធ្លាក់ចូលក្នុងល្បិចកលរបស់គេ (គឺបានធ្លាក់ចូលក្នុងអន្ទាក់របស់ស្តេចសីហនុ ដែលគ្រាន់តែជាទីងមោងរបស់ផាំ-យ៉ាំងដុង) ។

យើងអាចធ្វើការសន្និដ្ឋានបានថា ប្រសិនបើគ្មានការដួលរលំសម្តេចសីហនុនោះទេ ប្រទេសចិនច្បាស់ជាមិនអនុញ្ញាត ឲ្យពួកយួនកុម្មុយនិស្តធ្វើសង្គ្រាមទៅលើជនជាតិខ្មែរសោះឡើយ ។ ប៉ុន្តែសង្គ្រាមនៅប្រទេសកម្ពុជា គឺជា«ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ» ចាំបាច់ត្រូវតែបង្កើតឡើង យោងតាមបណ្តាំហូ-ជីមិញ ។ យួនមិនអាចចៀសវាងមិនធ្វើសង្គ្រាមនេះបានទេ ពីព្រោះយួនវាត្រូវការសង្កើតសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនមួយដ៏រឹងប៉ឹងមាំមួន ដើម្បីទប់ទល់នឹងប្រទេសចក្រពត្តិចិន ។ ម្ល៉ោះហើយការដួលរលំរបស់សម្តេចសីហនុ ដែលមើលទៅហាក់ដូចជាគ្រោះថ្នាក់នយោបាយ ឬជាចំណង់នៃព្រហ្មលិខិត តាមពិតគឺជាចំណង់របស់ជនជាតិយួន

សោះ ។ ព្រឹត្តិការណ៍នេះមិនអាចបង្កើតឡើង ឬផ្ដួងផ្ដើមដោយថៅកែណាម្នាក់ក្រៅពីជនឈ្មោះ ផាំ-ឃុាំងដុង នោះឯង ។ ព្រឹត្តិការណ៏នៃការដួលរលំខាងលើនេះ ដែលដើរស្របតាមខ្សែគោលការណ៍នយោបាយរបស់ជនជាតិយួន ក៏បានយកជ័យជំនះទៅលើការរារែករបស់ប្រទេសចិន ក្នុងប្រការរុញច្រានប្រទេសកម្ពុជា ឲ្យធ្លាក់ចូលក្នុងថ្លុកឈាមនៃវិនាសកម្ម ។៚

⌘ ⌘

⌘